**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន
និង សង្គ្រោះជនពិការដោយសារមីន

លេខ :....✓........../..អន../..អធម../..២០២៥

# សេចក្ដីប្រកាសព័ត៌មាន

## របស់អាជ្ញាធរមីន ឆ្លើយតបការចោទប្រកាន់គ្មានមូលដ្ឋានរបស់ថៃអំពីការដាក់មីនថ្មី

អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន (អាជ្ញាធរមីន) សូមបដិសេធ និងច្រានចោលទាំងស្រុង ចំពោះការចោទប្រកាន់របស់អ្នកនាំពាក្យកងទ័ពថៃថាកម្ពុជាបង្កប់មីនថ្មី ធ្វើឱ្យទាហានថៃជាន់បណ្ដាលឱ្យរបួសជាបន្តបន្ទាប់ ចំនួន៤លើក លើកទី១ នៅថ្ងៃទី១៦ កក្កដា លើកទី២ នៅថ្ងៃទី២៣ កក្កដា លើកទី៣ នៅថ្ងៃទី៩ សីហា និងលើកទី៤ នៅថ្ងៃទី១២ សីហា។ ជាមួយគ្នានេះ ថៃបានចោទប្រកាន់ថាកម្ពុជា រំលោភលើមាត្រា១ នៃអនុសញ្ញាហាមប្រាមការប្រើប្រាស់មីនប្រឆាំងមនុស្ស (អនុសញ្ញាអូតាវ៉ា)។

ក្នុងនាមជារដ្ឋភាគីនៃអនុសញ្ញាអូតាវ៉ា ដែលបច្ចុប្បន្នមាន១៦៥ប្រទេសជារដ្ឋភាគី កម្ពុជាត្រូវបានទទួលស្គាល់ជាអន្តរជាតិចំពោះសមិទ្ធផលនៃការបោសសម្អាតដ៏ច្រើនលើសលុប។ ជារឿយៗកងទ័ពថៃតែងចោទប្រកាន់កម្ពុជាដោយមិនបានផ្ដល់ភស្តុតាងជាក់លាក់ ឬរបាយការណ៍នៃការស៊ើបអង្កេតពិតប្រាកដនោះឡើយ។ ឆ្លើយតបទៅនឹងការចោទប្រកាន់មិនពិត និងគ្មានមូលដ្ឋានរបស់ថៃ អាជ្ញាធរមីនបានផ្ញើរលិខិតផ្លូវការជូនប្រធានអនុសញ្ញាអូតាវ៉ា ដើម្បីជម្រាបពីសាវតា និងប្រវត្តិដែលថៃតែងចិញ្ចឹមចិត្តឈ្លានពានកម្ពុជាដោយប្រើរូបភាពថាកម្ពុជាដាក់មីនថ្មី។ លិខិតនោះមានអត្ថន័យ សង្ខេបដូចខាងក្រោម៖

១. ថៃបានយកបញ្ហាមីនធ្វើនយោបាយ ចោទប្រកាន់ម្ដងហើយម្ដងទៀត ដើម្បីជាលេសប្រើកម្លាំងយោធាឈ្លានពានកម្ពុជា។ ក្នុងឆ្នាំ ២០០៨ ថៃបានចោទប្រកាន់ស្រដៀងគ្នាអំពីការដាក់មីនថ្មី ដែលការចោទនេះគឺគ្មានភស្តុតាងច្បាស់លាស់។ ទាំងនេះ គឺជាយុទ្ធសាស្ត្រដែលថៃប្រើប្រាស់ ដើម្បីបង្កឱ្យស្ថានភាពមានភាពតានតឹងនិងឈានទៅប្រើកម្លាំងប្រដាប់អាវុធ។ ក្នុងន័យនេះ កម្ពុជា បានផ្ដល់នូវកំណត់ចំណាំថា៖

- ប្រសិនគ្រោះថ្នាក់ឬឧប្បត្តិហេតុកើតឡើងនៅក្នុងទឹកដីថៃ ថៃត្រូវទទួលខុសត្រូវដោយខ្លួនឯង។ កម្ពុជាសូមបដិសេធដាច់ខាត រាល់ការប៉ុនប៉ង ចោទប្រកាន់ ឬទំលាក់កំហុសដោយគ្មានមូលដ្ឋាន ឬប្រើជាលេសដើម្បីកេងប្រវ័ញ្ច ផលប្រយោជន៍ នយោបាយ ឈានទៅឈ្លានពានដោយប្រើកម្លាំងយោធា
- ប្រសិនគ្រោះថ្នាក់ ឬឧប្បត្តិហេតុកើតឡើងនៅក្នុងទឹកដីកម្ពុជា ឬតំបន់ព្រំដែនមិនទាន់បញ្ចប់ការខណ្ឌសីមា មានន័យថា ថៃបានបំពានអនុស្សរណៈនៃការយោគយល់គ្នាឆ្នាំ២០០០ និងកិច្ចព្រមព្រៀងក្នុងកិច្ចប្រជុំវិសាមញ្ញគណៈកម្មាធិការព្រំដែនទូទៅ ថ្ងៃទី៧ ខែសីហា ឆ្នាំ ២០២៥។ តំបន់នេះ ជាតំបន់មានមីនច្រើនដែលបានបន្សល់ទុកដោយសង្គ្រាមក្នុងអំឡុងទសវត្សរ៍ឆ្នាំ ១៩៧០ ដល់ ១៩៨០ ហើយបច្ចុប្បន្ន តំបន់នេះកំពុងមានការស្រាវជ្រាវ និងត្រូវបោសសម្អាត ប៉ុន្តែ

ការបោសសម្អាតក្នុងតំបន់នេះ មានការលំបាកដោយសារស្ថានភាពព្រៃភ្នំ និងបញ្ហាខណ្ឌសីមាព្រំដែនដែលមិនទាន់បញ្ចប់។ ដោយមូលហេតុនេះ រួមជាមួយការគំរាមកំហែងដោយយោធាថៃ និងដើម្បីសហគមន៍មានសុវត្ថិភាព ចាំបាច់ត្រូវបញ្ចប់ការខណ្ឌសីមាព្រំដែនជាមុន។ កម្ពុជាបដិសេធដាច់ខាតចំពោះចេតនាចោទប្រកាន់មិនពិត ឬប្រើប្រាស់បញ្ហាមីន ជាលេសដើម្បីកេងចំណេញនយោបាយ ឬរំលោភដែនអធិបតេយ្យភាពប្រទេសដទៃ។

២. កម្ពុជា មិនបានប្រើប្រាស់ ហើយនឹងមិនប្រើប្រាស់មីនប្រឆាំងមនុស្សឡើយ ហើយកម្ពុជាបដិសេធ និងថ្កោលទោសយ៉ាងខ្លាំងចំពោះការចោទប្រកាន់មិនពិតអំពីការប្រើប្រាស់មីន ដើម្បីជាហេតុផលឈ្លានពាន និងរំលោភដែនអធិបតេយ្យភាពរបស់កម្ពុជា។

៣. កម្ពុជា សូមអំពាវនាវដល់រដ្ឋភាគីអនុសញ្ញាអូតាវ៉ាទាំងអស់៖

- ចូលរួមការពារបូរណភាពអនុសញ្ញាអូតាវ៉ា និងច្រានចោលដាច់ខាតចំពោះការចោទប្រកាន់ដោយគ្មានមូលដ្ឋានរវាងរដ្ឋភាគី ជាក់ស្តែងករណីថៃ ចោទកម្ពុជា
- ចូលរួមជម្រុញឱ្យថៃដោះលែងជាបន្ទាន់ នូវទាហានកម្ពុជាដែលនៅសេសសល់ទាំងអស់ដែលថៃបានចាប់ខ្លួន និងឃុំឃាំងដោយខុសច្បាប់ ព្រោះវាជាការរំលោភបំពានច្បាប់អន្តរជាតិ កិច្ចព្រមព្រៀងឈប់បាញ់ និងគោលការណ៍មនុស្សធម៌
- ជំរុញឱ្យថៃគោរពយ៉ាងពេញលេញ នូវកិច្ចព្រមព្រៀងឈប់បាញ់ ថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០២៥ និងលទ្ធផលកិច្ចប្រជុំវិសាមញ្ញគណៈកម្មាធិការព្រំដែនទូទៅ ថ្ងៃទី ៧ ខែសីហា ឆ្នាំ ២០២៥ និងបញ្ឈប់រាល់ការឈ្លានពានមកលើកម្ពុជា
- ជំរុញការបន្ត និងពន្លឿនការកំណត់ខណ្ឌសីមាព្រំដែន ដែលស្របតាមសន្ធិសញ្ញាបារាំង-សៀម ឆ្នាំ១៩០៤, ១៩០៧ និងអនុស្សរណៈយោគយល់គ្នាឆ្នាំ២០០០ ដែលជាមូលដ្ឋានគ្រឹះសម្រាប់ដោះស្រាយបញ្ហាប្រកបដោយសន្តិភាព បញ្ចៀសការប៉ះទង្គិចប្រដាប់អាវុធ ធ្វើឱ្យការបោសសម្អាតមីនប្រព្រឹត្តទៅបានដោយរលូន
- ជម្រុញឱ្យថៃទទួលយកនូវការប្រើប្រាស់វិធានការច្បាប់ ចំពោះចំណុចព្រំដែនដែលមានជម្លោះទាំង៤ តាមរយៈតុលាការយុត្តិធម៌អន្តរជាតិ ដើម្បីធានាបាននូវដំណោះស្រាយច្បាស់លាស់ មានសន្តិភាព ដែលអំណោយផលដល់ការបោសសម្អាតមីន
- ជំរុញឱ្យថៃបញ្ឈប់ការប្រើប្រាស់គ្រាប់បែកចង្កោម អាវុធដែលបញ្ចេញសារជាតុគីមីពុល គ្រាប់ទម្លាក់ពីលើអាកាសប្រភេទ MK series 80 ការចាប់និងឃុំខ្លួនទាហានកម្ពុជាក្រោយបទឈប់បាញ់ និងការរំលោភបំពានលើទាហានកម្ពុជាក្នុងអំឡុងពេលឃុំខ្លួន។

ថ្ងៃសុក្រ ៦រោច ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែសីហា ឆ្នាំ២០២៥

អាជ្ញាធរមីន

CMAA